**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រមព្រហ្មទណ្ឌ**

លេខ ៧៣ ក្រ.១១ "ង"

ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

-សំណុំរឿងព្រហ្មទណ្ឌលេខ ៧១៧៩

ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨

-សំណុំរឿងស៊ើបសួរលេខ ៤១៨៣

ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨

-សំណុំរឿងជំនុំជម្រះលេខ៣១៥១

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៩

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនា ការជាសាធារណៈ នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ០៨ និង០០នាទីព្រឹក នៅសាលសវនាការទី៣ ដោយមានសមាសភាព ៖

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ៧១៧៩ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] យ៉ាំងចូវ ភេទប្រុស អាយុ២៤ឆ្នាំ ជនជាតិវៀតណាម មុខរបរ ផ្ញើសំណង់ ទីកន្លែងកំណើត [redacted] ប្រទេសវៀតណាម មានទីលំនៅមុនពេលឃាត់ខ្លួនផ្ទះលេខ ១៥៩ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យ៉ាំងវ៉ា (ស) ម្ដាយឈ្មោះ [redacted] ធីស៊ីង (រ) នៅលីវ ទោសពីមុនគ្មាន ជាតិជន ។

ឃាត់ខ្លួនថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ និងដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៩៣៨២ (ឃ).ដ.ឃ.ដ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

២-ឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ុំណេត ភេទស្រី អាយុ៣៥ឆ្នាំ ជនជាតិវៀតណាម មុខរបរ លក់ដូរ ទីកន្លែងកំណើត ខេត្តអានយ៉ាង ប្រទេសវៀតណាម មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៥៩ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] យ៉ាំងសឹង (ស) ម្ដាយឈ្មោះ [redacted] ធីលុង (រ) ប្ដីឈ្មោះ [redacted] សុខធឿន មានកូន០២នាក់ ទោសពីមុនគ្មាន ជាតិជន ។

ឃាត់ខ្លួនថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៨ និងដីកាបង្គាប់ឱ្យឃុំខ្លួនលេខ៩៣៨៣ (ឃ).ដ.ឃ.ដ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ។

ជាប់ចោទពីបទ៖ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌ

ទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត។

៣-ឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិវៀតណាម មុខរបរស្ត្រីបម្រើផ្លូវភេទ ទីកន្លែងកំណើត [redacted] ប្រទេសវៀតណាម មានទីលំនៅសព្វថ្ងៃផ្ទះលេខ១៥៩ ផ្លូវលេខ៥៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទោសពីមុនគ្មាន ជាទីតិជន ។ (ក្រៅឃុំ)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៣៥៧ (ដ).ង.ច.ន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ។

ជាប់ចោទពីបទ៖ **មិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង** ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិ**មាត្រា៥២៩** នៃក្រមព្រហ្មទណ្ឌ ។

លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីហៀង ។

៤-ឈ្មោះ [redacted] ចាន់ធូ ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃ [redacted] រាជធានីភ្នំពេញ ទោសពីមុនគ្មាន ជាទីតិជន ។ (ក្រៅឃុំ)

ដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៣៥៦ (ដ).ង.ច.ន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ។

ជាប់ចោទពីបទ៖ **ផ្តើមគំនិតនៃអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិ**មាត្រា២៨** និង**មាត្រា២២៤** នៃក្រមព្រហ្មទណ្ឌ ។

លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ។

ដោយមានលោក [redacted] សេង ជាអ្នកបកប្រែភាសាឱ្យជនជាប់ចោទ

**<u>អង្គហេតុនៃរឿងមានដូចតទៅ</u>**

កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅចំណុចបន្ទប់ជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានករណី **ផ្តើមគំនិតនៃអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ,ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** និង **មិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង** មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទចំនួន០៤នាក់មានឈ្មោះ [redacted] យ៉ាំងចូវ , ឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត , ឈ្មោះ [redacted] ធីហៀង និងឈ្មោះ [redacted] ចាន់ធូ ។ មុនពេលកើតហេតុនៅដើមឆ្នាំ២០១៧ ជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ បានមកជួលផ្ទះបើកមុខរបរដាក់ស្រីបម្រើផ្លូវភេទ ដែលមានឈ្មោះ [redacted] ធីយុង ហៅ យុង និងឈ្មោះ [redacted] ធីហៀង ជាអ្នកទទួលភ្ញៀវ ហើយឈ្មោះ [redacted] ចាន់ធូ បានឱ្យឈ្មោះ [redacted] យ៉ាំងចូវ ជាអ្នកគ្រប់គ្រងមើលការខុសត្រូវលើនារីទាំងពីរនាក់នោះ នៅពេលដែលនារីទាំងពីរនាក់នោះពុំព្រមទទួលភ្ញៀវ ។ លុះក្រោយមកនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្រាប់តែជនរងគ្រោះឈ្មោះ [redacted] ធីយុង ហៅ យុង មានអាការៈពុំសូវស្រួលខ្លួនមិនព្រមទទួលភ្ញៀវ ឈ្មោះ [redacted] ចាន់ធូ មានការខឹងសម្បារបានបញ្ជាឱ្យឈ្មោះ ង្វៀង យ៉ាំងចូវ និងឈ្មោះ [redacted] ធីហៀង វាយទាត់ធាក់ទៅលើឈ្មោះ [redacted] ធីយុង ហៅ យុង បណ្តាលឱ្យស្លាប់ ។ បន្ទាប់ពីបានដឹង

ថាឈ្មោះ [redacted] ធីយុង ហៅ យុង ស្លាប់ហើយនោះឈ្មោះ [redacted] យ៉ាំងចូវ បានឱ្យឈ្មោះ [redacted] ធីហៀង ជួយយកកន្ទេលក្អួយរុំសពជនរងគ្រោះ ។ លុះវេលាយប់នាថ្ងៃខែឆ្នាំដដែលឈ្មោះ [redacted] ចាន់ធូ បានខ្ចីម៉ូតូរបស់គេមកឱ្យឈ្មោះ [redacted] យ៉ាំងចូវ ទុកដឹកសពយកទៅបោះចោល ។ បន្ទាប់មកជនជាប់ចោទឈ្មោះ [redacted] ធីហៀង បានយករទេះរុញអេតចាយដែលគេទុកចោលនៅក្បែរនោះមកដាក់សព ហើយបានប្រមូលសម្លៀកបំពាក់របស់ជនរងគ្រោះឈ្មោះ [redacted] ធីយុង ហៅ យុង ដាក់ក្នុងថង់ពណ៌ខ្មៅមួយរួចយកទៅដាក់ក្នុងរទេះអេតចាយជាមួយសពជនរងគ្រោះ ហើយឈ្មោះ [redacted] យ៉ាំងចូវ ដឹកឈ្មោះ [redacted] ធីហៀង ហើយឈ្មោះ [redacted] ធីហៀង ជាអ្នកអូសរទេះអេតចាយដែលដាក់សពជនរងគ្រោះទៅតម្កល់ទុកនៅវត្តទឹកថ្លា ។ លុះព្រឹកឡើងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ សមត្ថកិច្ចបានទទួលព័ត៌មានពីលោកតាអាចារ្យថាមានមនុស្សស្លាប់រួចសមត្ថកិច្ចបានចុះទៅពិនិត្យសាកសព និងបានបូជានៅពេលនោះ ព្រោះសពមិនអាចរក្សាទុកយូរបាន ។ បន្ទាប់មកនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៨ សមត្ថកិច្ចបានស្រាវជ្រាវតាមរយៈម៉ូតូដែលដឹកសព និងបាននាំខ្លួនឈ្មោះ [redacted] វឿន ដែលជាម្ចាស់ម៉ូតូមកសួរនាំទើប សមត្ថកិច្ចឈានដល់ការឃាត់ខ្លួនជនជាប់ចោទចំនួន ០២នាក់ដែលមានឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត និងឈ្មោះ [redacted] យ៉ាំងចូវ ។ ចំណែកឈ្មោះ [redacted] ចាន់ធូ និងឈ្មោះ [redacted] ធីហៀង បានរត់គេចខ្លួនបាត់ ។

-បានឃើញ របាយការណ៍សំយោគលេខ២០៧/១៨ រ.ប.គ ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់អធិការដ្ឋាននគរបាលខណ្ឌសែនសុខនៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ៤២១២ អ.យ.ត ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ២៣៣៦ អ.យ.ត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៣៤៨៤ (ង).ង.ជ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **ធីយុង** ហៅ [redacted] **ស៊ីណេត** បានឆ្លើយថា៖ ចម្លើយដែលខ្លួនបានឆ្លើយនៅសមត្ថកិច្ចអធិការដ្ឋាននគរបាល ខណ្ឌសែនសុខ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ខ្លួនមិនទទួលស្គាល់ទេដោយមូលហេតុការសួរចម្លើយប៉ូលីស ស្រែកសំឡុតគំរាម និងបង្ខំឱ្យឆ្លើយ ។ ពាក់ព័ន្ធនឹងការសម្លាប់ជនរងគ្រោះឈ្មោះ យុង នោះ ខ្លួនមិនដឹងថានៅពេលណាទេ ហើយអ្នកណាជាអ្នកសម្លាប់ក៏ខ្លួនមិនបានដឹងដែរ ។ នៅថ្ងៃដែលឈ្មោះ យុង ស្លាប់មានឈ្មោះ ហៀង ភេទស្រី ត្រូវជាអ្នកជិតខាងខ្លួនបានស្រែកប្រាប់ខ្លួនជាភាសាវៀតណាមថា "ឈ្មោះ យុង ស្លាប់ ហើយ គឺនៅម៉ោងប្រហែល៦ ល្ងាច" ។ តែខ្លួនមិនបានសួរនាំពីមូលហេតុនៃការស្លាប់របស់ឈ្មោះ យុង នោះទេ ។ ពេលយប់ជ្រៅឈ្មោះ ង្វៀង យ៉ាំងចូវ បើកម៉ូតូឌុបខ្លួនដោយខ្លួនជាអ្នកអូសរទេះដាក់សពជនរងគ្រោះយកទៅវត្តទឹកថ្លា ។ ពេលទៅដល់វត្ត ខ្លួនបានប្រគល់សពឱ្យអាចារ្យ និងជូនលុយគាត់ចំនួន ៤០០.០០០ (សែសិបម៉ឺន) រៀល សម្រាប់ធ្វើបុណ្យ ទើបខ្លួនត្រឡប់មកផ្ទះវិញ ។ រឿងសម្លាប់មនុស្ស ខ្លួនមិនដឹងថាអ្នកណាជាជនដៃដល់ទេ ហើយខ្លួនក៏មិនបានចូលរួមនឹងការស្លាប់នេះដែរ ។ រឿងនេះ ខ្លួនមិនបានរាយការណ៍ជូនសមត្ថកិច្ចទេ ព្រោះខ្លួនមិនចេះអក្សរ និងច្បាប់ទេ ។ ឈ្មោះ ហៀង ភេទស្រី ត្រូវបានសមត្ថកិច្ចហៅ ទៅសួរនាំដែរ តែពេលសួររួចសមត្ថកិច្ចដោះលែងទៅវិញ ។ ប៉ុន្តែជនរងគ្រោះនៅក្នុងផ្ទះជាមួយ



Scanned with CamScanner

ឈ្មោះ ហៀង ។ ឯឈ្មោះ [redacted] យ៉ាំងចូវ ខ្លួនឧស្សាហ៍ឃើញគាត់ចេញចូលផ្ទះឈ្មោះ [redacted] ណាស់ ។ ខ្លួនមិនមានជាប់សាច់ញាតិជាមួយនឹងឈ្មោះ ចូវ និងឈ្មោះ ធូ ទេ។

-ជនជាប់ចោទឈ្មោះ [redacted] **យ៉ាំងចូវ** បានឆ្លើយនាពេលសវនាការថា៖ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោង០៦ល្ងាចឈ្មោះ [redacted] ធីយុង បានប្រាប់ខ្លួនថា "ជនរងគ្រោះបានស្លាប់ដោយសារជម្ងឺ" ។ ឈ្មោះ [redacted] ធីហៀង បានហៅខ្លួន និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ដែលជាអ្នកជិតខាងឱ្យមកជួយ ។ ពេលឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានមកដល់ក៏បានប្រាប់ឱ្យជួយដឹកសពទៅបូជានៅវត្តទឹកថ្លា ។ បន្ទាប់មកខ្លួនឃើញរទេះអូសអេតចាយនៅ មុខផ្ទះ ហើយខ្លួនក៏បានជួលម៉ូតូមកអូសរទេះនោះយកដាក់សពអូសទៅវត្តដោយខ្លួនជាអ្នកបើកបរ ហើយឈ្មោះ [redacted] ធីយុង ហៅ ចិន ស៊ីណេត ជាអ្នកអូសរទេះពីក្រោយ ។ លុះទៅដល់វត្តទឹកថ្លាលោកអាចារ្យបានសុំមើលលិខិតអនុញ្ញាតបូជាសព ។ ប៉ុន្តែពួកខ្លួនពុំមានលោកអាចារ្យក៏ឱ្យពួកខ្លួនទុកសពនៅទីនោះ ហើយពួកខ្លួនក៏ត្រឡប់មកផ្ទះវិញ ។ លុះនៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ក៏មានសមត្ថកិច្ចមកឃាត់ខ្លួននិងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត តែម្តង ។ ខ្លួនមិនបានវាយទៅលើជនរងគ្រោះឈ្មោះ យុង នោះទេ ។ ខ្លួនគ្រាន់តែដឹងថាឈ្មោះ យុង មានជម្ងឺរ៉ាំរ៉ៃយូរមកហើយ។ ខ្លួនមានមុខរបរជាកម្មករដែលមានប្រាក់ខែក្នុង០១ខែ១៣០.០០០ (ដប់បីម៉ឺន) រៀល។ ខ្លួនមិនស្គាល់ឈ្មោះ ង្វៀង ធីយុង ហៅ [redacted] ស៊ីណេត និងឈ្មោះ [redacted] ចាន់ធូ ទេ។ ខ្លួនពុំបានវាយលើជនរងគ្រោះឈ្មោះ យុង នោះទេ។ ឈ្មោះ ង្វៀង ធីហៀង មានផ្ទះរំលងពីផ្ទះខ្លួនពី២ទៅ៣ផ្ទះ ។ ខ្លួនមិនបានដឹងថាផ្ទះកោសជប់ម៉ាស្សាមានគ្នាប៉ុន្មាននាក់ទេ គ្រាន់តែខ្លួនបានឃើញមានមនុស្ស០២នាក់គឺជនរងគ្រោះឈ្មោះ យុង និងឈ្មោះ ហៀង ប៉ុណ្ណោះ។

-អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ធីហៀង** បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ ខ្លួនបានចូលមកប្រទេសកម្ពុជានៅអំឡុងឆ្នាំ២០១៣ ពេលខ្លួនមកដល់ប្រទេសកម្ពុជាបានជួបជាមួយឈ្មោះ [redacted] ធីយុង ភេទស្រី ជាជនរងគ្រោះ , ឈ្មោះ [redacted] យ៉ាំងចូវ ភេទប្រុស និងឈ្មោះ [redacted] ធីធូ ភេទស្រី ។ ឈ្មោះ [redacted] ធីធូ ក៏ជួលផ្ទះលេខ១៥៨ ម្តុំគ្រឡោកបែក បើកបនស្រីដោយឈ្មោះ ធូ ជាមេបន ។ ខ្លួននិងឈ្មោះ [redacted] ធីយុង (ជនរងគ្រោះ) ជាអ្នកបម្រើផ្លូវភេទដោយមានឈ្មោះ [redacted] យ៉ាំងចូវ ជាអ្នកមើលការខុសត្រូវលើរូបខ្លួន និងឈ្មោះ [redacted] ធីយុង បន្ទាប់ពីឈ្មោះ [redacted] ធីធូ ជាមេបន ។ ចាប់ពីពេល ខ្លួននិងជនរងគ្រោះបម្រើផ្លូវភេទនៅក្នុងផ្ទះនោះមក រូបខ្លួននិងជនរងគ្រោះតែងតែរងគំនាបពីឈ្មោះ [redacted] ធីធូ ជាមេបន និងឈ្មោះ [redacted] យ៉ាំងចូវ បានវាយធ្វើបាបជាញឹកញាប់នៅពេលដែលខ្លួន និងជនរងគ្រោះមិនស្រួលខ្លួនមិនព្រមដេកជាមួយប្រុស ។ លុះដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោងប្រហែល២០និង០០នាទី ឈ្មោះ [redacted] ធីយុង (ជនរងគ្រោះ) មិនព្រមដេកជាមួយភ្ញៀវដោយមិនស្រួលខ្លួនឈ្មោះ [redacted] យ៉ាំងចូវ បានយកដំបងឫស្សីសម្រាប់អេះខ្នងវាយធ្វើទារុណកម្មលើរាងកាយឈ្មោះ [redacted] ធីយុង ចាប់បោកក្បាលបុកជញ្ជាំងបែកគុម្ពត្រចៀក និងធាក់ឱ្យដួលផ្កាប់មុខបែកថ្ងាស់ ។ ពេលនោះ ខ្លួននៅក្បែរនោះតែមិនហ៊ានជួយខ្លាចឈ្មោះ [redacted] វាយដែរ ។ រហូតដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោងប្រហែល១៦និង០០នាទីឈ្មោះ [redacted] ធីយុង បានស្លាប់ខ្លួនបានឃើញក៏មានការអាណិតអាសូរនិងបញ្ជារពីឈ្មោះ ចូវ ខ្លួនបានយកកន្ទេលរុំសាកសព ហើយចេញមកប្រាប់ឈ្មោះ [redacted] ធីយុង ជាបងស្រីរបស់ឈ្មោះ ចូវ ថាជនរងគ្រោះស្លាប់ឱ្យរករ៉ឺម៉កដឹកសាកសព ។ រហូតដល់ម៉ោងប្រហែល២១ និង០០នាទី ខ្លួននិងឈ្មោះ [redacted] យ៉ាំងចូវ បានសែងសាកសពដាក់រ៉ឺម៉ក ហើយឈ្មោះ [redacted] យ៉ាំងចូវ ជាអ្នកបើកម៉ូតូ ។ ចំណែកឈ្មោះ [redacted] ធីយុង អង្គុយក្រោយអូសរ៉ឺម៉កដឹកសាកសពយកទៅចោល ។ ពេលឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ត្រឡប់មកវិញប្រាប់ថា "សាកសពជនរងគ្រោះយកទៅទុកចោលនៅវត្តទឹកថ្លា" ។ បន្ទាប់មក ខ្លួនមានការភ័យខ្លាចក៏

-ជនជាប់ចោទឈ្មោះ [redacted] ថានធូ (អវត្តមាន) ។

-ចម្លើយរបស់សាក្សីឈ្មោះ [redacted] យ៉ាត់ បានឆ្លើយថា៖ រយៈពេលដែលខ្លួនមករស់នៅទីនេះជិត ១០ឆ្នាំមក ហើយដោយត្រូវជាអ្នកក្បែរខាងរបស់ផ្ទះកើតហេតុ ។ ខ្លួនរស់នៅក្បែរគ្នាពុំដែលស្គាល់ឈ្មោះរបស់ផ្ទះកោសជប់នោះទេ ដោយគ្រាន់តែដឹងថាផ្ទះនោះឧស្សាហ៍មានភ្ញៀវប្លែកមុខចេញចូលជាញឹកញាប់ ។ ខ្លួនបានដឹងថាផ្ទះកោសជប់ក្បែរ ខាងនេះឧស្សាហ៍លឺសម្លេងប្រកែកគ្នាតឹងសរសៃកជាភាសាវៀតណាម ប៉ុន្តែមិនដឹងថាគេប្រកែកគ្នារឿងអ្វីដែរ ផ្ទះកោសជប់នោះមានស្ត្រីពីរនាក់ ។ ជាធម្មតាផ្ទះរបស់ខ្លួនតែងតែបិទទ្វារឈប់លក់ដូរតុទូនៅម៉ោង១៨និង០០នាទី ហើយក៏ចាប់អារម្មណ៍ថា ផ្ទះកើតហេតុតែងតែបើកទ្វារផ្ទះមានភ្ញៀវចេញចូលម៉ោងប្រហែល១៨និង០០នាទីដែរ ។ ដោយជាធម្មតាពេលព្រឹកនិងពេលថ្ងៃតែងតែបិទទ្វារជិតពុំមានទំនាក់ទំនងរាប់អានស្គាល់ជាមួយខ្លួនដែលរស់នៅក្បែរខាងឡើយ ។ ខ្លួនឧស្សាហ៍ឃើញឈ្មោះ យុង ចេញចូលផ្ទះរបស់នារីរងគ្រោះនោះនៅពេលយប់ ។ ផ្ទះរបស់ឈ្មោះ យុង នៅខាងត្បូងផ្ទះរបស់ជនរងគ្រោះ ហើយផ្ទះរបស់ឈ្មោះ យុង លក់បាយ ។

-សាក្សីឈ្មោះ [redacted] ផាត់ បានឆ្លើយថា៖ នៅថ្ងៃខែមិនចាំក្នុងឆ្នាំ២០០០ ខ្លួនបានចូលធ្វើការ ជាអាចារ្យនៅក្នុងវត្តទឹកថ្លា ទទួលខាងផ្នែកតម្កល់សពប្រចាំនៅវត្តតែម្នាក់ឯង ។ កន្លងមកមុនពេលទទួលសព ខ្លួនបានមានការសួរនាំរកឯកសារផ្លូវច្បាប់ទើបខ្លួនទទួល ព្រមទាំងមានក្រុមគ្រួសារសពនៅចូលរួម ។ ដោយឡែកនៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ពេលយប់រំលងអាធ្រាត មានមនុស្សស្រីម្នាក់បើកម៉ូតូសណ្តោងរទេះដឹកសពមនុស្សស្រីម្នាក់ចូលមកក្នុងវត្តកន្លែងតម្កល់សពរួចខ្លួនបានសួរនាំថា "យកសពមកទីនេះមានលិខិតស្នាមដែរឬទេ? ហើយគាត់បានឆ្លើយថា "ចាំម៉ោង ៩ព្រឹកនឹងយកលិខិតស្នាមមកប្រគល់ឱ្យ" និងបានយកប្រាក់ចំនួន ៤០០.០០០ (សែសិបម៉ឺន) រៀល យកមកផ្ញើទុកនឹងខ្លួន ។ ខ្លួនបានយកប្រាក់នោះទៅប្រគល់ឱ្យលោកតែម្តង ។ បន្ទាប់មកមនុស្សស្រីនោះបានលើកសពមកតម្កល់រួចរាល់ ហើយទើបគាត់ជិះម៉ូតូត្រឡប់ទៅវិញបាត់ ។ រហូតដល់ម៉ោងប្រហែល ១១និង១០នាទី ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ មិនឃើញមនុស្សស្រីម្នាក់នោះយកលិខិតស្នាមមកប្រគល់ឱ្យទើបខ្លួនបានទូរស័ព្ទផ្តល់ព័ត៌មានទៅប្រាប់សមត្ថកិច្ចមូលដ្ឋាន ។

-សាក្សីឈ្មោះ [redacted] សុផល បានឆ្លើយថា: ខ្លួនជានាយប៉ុស្តិ៍រដ្ឋបាលនគរបាលទឹកថ្លា ។ ខ្លួនបានទទួលព័ត៌មានថានៅវត្តមានសព ទើបខ្លួនបានទំនាក់ទំនងទៅខាងបច្ចេកទេសកោសលវិច្ច័យ ដើម្បីមកពិនិត្យស្លាកស្នាមនៃការស្លាប់ ។ តាមការស្រាវជ្រាវបានបញ្ជាក់ថាជាឃាតកម្ម។ បន្ទាប់មកក៏បានធ្វើការស្រាវជ្រាវតាមតាអាចារ្យ និងឡានពេទ្យដែលដឹកសពក៏បានធ្វើការកំណត់មុខសញ្ញា ឃើញរទេះអេតចាយដោយធ្វើការសាកសួរតាមផ្លូវរទេះភ្លើង ក៏បានឃាត់ខ្លួនបុរសជនជាតិវៀតណាមយកមកធ្វើការសាកសួរ ។ បុរសនោះក៏បានសារភាពថា ខ្លួនពិតជាបានធ្វើទារុណកម្មលើនារីរងគ្រោះ ហើយនារីរងគ្រោះនោះក៏មានជម្ងឺប្រចាំកាយផងដែរ ។ បន្ទាប់មកក៏បានឈានទៅធ្វើការឃាត់ខ្លួននារីឈ្មោះ ធីយុង ម្នាក់ទៀត មកធ្វើការសាកសួរ ។ ក្រោយមកក៏បានបញ្ជូនជនជាប់ចោទទាំងពីរនេះឱ្យទៅខាងជំនាញ ដើម្បីធ្វើការបន្តទៀត។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាលីន បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ ផ្ទះលេខ១៥៨ ផ្លូវលេខ៩៨ ភូមិ១៦ សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់ខ្លួន ដែលបានជួលឱ្យទៅឈ្មោះ ចន្ទ



Scanned with CamScanner

ភេទស្រី អាយុប្រហែល៣៥ឆ្នាំ ជនជាតិវៀតណាម អស់រយៈពេលប្រហែល៥ឆ្នាំមកហើយ ដោយបានកម្រៃ ១៥០ (មួយរយហាសិប) ដុល្លារអាមេរិក ក្នុង០១ខែ ។ ជារៀងរាល់ខែឈ្មោះ ចន្ទ តែងតែប្រើម៉ូតូឌុបយកលុយកមកឲ្យខ្លួនពុំដែលខានទេ ។ ខ្លួនមិនដែលដឹងថាឈ្មោះ ចន្ទ ជួលផ្ទះរបស់ខ្លួនទៅប្រកបមុខរបរអ្វីទេ ព្រោះតែគេបង់លុយឲ្យមិនដែលខាន ទើបតែរយៈពេល០៣ខែនេះ ខ្លួនមិនទាន់ទទួលបានលុយថ្លៃផ្ទះទេ ដោយឈ្មោះ ចន្ទ ប្រាប់ថាជំពាក់សិនមិនទាន់មានលុយទេ ។ រហូតដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១០ និង០០នាទី ខ្លួនបានទទួលទូរស័ព្ទពីអ្នកជិតខាងថាផ្ទះរបស់ខ្លួនជួលឲ្យគេនោះមានបញ្ហា ។ ខ្លួនក៏ប្រញាប់មកមើលភ្លាមៗតែម្តងដោយមិនដឹងថាជាបញ្ហាអ្វីឡើយ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] **មុន្នីទិដ្ឋា** បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល០១និង០០នាទីមុនពេលកើតហេតុ ខ្លួនបានបើករថយន្តសម្រាប់ដឹកសាកសពមនុស្សប្រុសម្នាក់ចេញពីវត្តស្ទឹងមានជ័យយកមកតម្កល់នៅវត្តទឹកថ្លា ។ ពេលដឹកមកដល់វត្តទឹកថ្លា ខ្លួននិងឈ្មោះ ហេង បាននាំគ្នាលើកសាកសពមនុស្សប្រុសម្នាក់នោះដាក់សាលតម្កល់សាកសពរួចរាល់ ហើយបម្រុងបើករថយន្តចេញទៅវិញ ស្រាប់តែឃើញមនុស្សប្រុសម្នាក់ និងមនុស្សស្រីម្នាក់ដោយមនុស្សប្រុសជាអ្នកបើកម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ សណ្តោងរទេះដឹកសាកសពមនុស្សស្រីម្នាក់មកឈប់នៅក្បែររថយន្តដឹកសពរបស់ខ្លួន ហើយមនុស្សស្រីនោះបានដើរមកជួបអាចារ្យនៅកន្លែងតម្កល់សពក្នុងវត្តទឹកថ្លា ។ ពេលនោះ ខ្លួនបានសួរមនុស្សប្រុសនោះថា “ដឹកសពមកពីកន្លែងណា?” ។ ប៉ុន្តែគាត់មិនចេះនិយាយភាសាខ្មែរទេ ហើយមនុស្សស្រីម្នាក់នោះបានដើរត្រឡប់មកវិញលើកសពចេញពីក្នុងរទេះ ដោយឃើញពិបាកពេក ខ្លួននិងឈ្មោះ ហេង បានជួយលើកយកមកដាក់នៅសាលតម្កល់សព ។ បន្ទាប់មកឈ្មោះ ហេង បានយកទូរស័ព្ទដៃមកថតម៉ូតូសណ្តោងរទេះដឹកសាកសពមនុស្សស្រីនោះ ។ បន្ទាប់មក ខ្លួននិងឈ្មោះ ហេង បានបើករថយន្តត្រឡប់ទៅវិញ ។ ភិនភាគរបស់មនុស្សស្រីមានរាងទាប សម្បុរស មាឌរាងមានសាច់ អាយុប្រហែល៣៧ឆ្នាំ និយាយភាសាខ្មែរមិនសូវច្បាស់កម្ពស់ប្រហែល ១.៥៥ម៉ែត្រ ពាក់ម៉ាស់មុខ ពាក់អាវដៃវែងសាច់ក្រណាត់ពណ៌ផ្កាឈូក ស្លៀកខោជើងវែងពណ៌ខ្មៅ ។ ចំណែកមនុស្សប្រុសអាយុប្រហែល២០ឆ្នាំ មិនចេះនិយាយភាសាខ្មែរ មានកាយវិការដូចមនុស្សស្រីមាឌរាងមានសាច់ សម្បុរស កម្ពស់ប្រហែល ១,៦៥ម៉ែត្រ សក់ស្កូតរាងវែងពណ៌ខ្មៅ ទម្រង់មុខមូល ចិញ្ចើមក្រាស់ ភ្នែកតូចរាងតឹង ច្រមុះតូចទាល មាត់តូច ចង្ការស្រួច ពាក់អាវដៃវែងពណ៌សលាយខ្មៅមានរូបផ្កាយមានមួកពីក្រោយស្លៀកខោជើងវែងពណ៌ខ្មៅ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ **ប្រូវ ម៉េងហេង** បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល០១និង០០នាទីរំលងអាធ្រាត មុនពេលកើតហេតុ ខ្លួននិងឈ្មោះ ទិដ្ឋា បានបើករថយន្តសម្រាប់ដឹកសាកសពមនុស្សប្រុសម្នាក់ចេញពីវត្តស្ទឹងមានជ័យយកមកតម្កល់នៅវត្តទឹកថ្លា ។ ពេលដឹកមកដល់វត្តទឹកថ្លា ខ្លួននិងឈ្មោះ ទិដ្ឋា បាននាំគ្នាលើកសាកសពមនុស្សប្រុសម្នាក់នោះដាក់សាលតម្កល់សាកសពរួចរាល់ ហើយបម្រុងបើករថយន្តចេញទៅវិញ ។ ស្រាប់តែឃើញមនុស្សប្រុសម្នាក់និងមនុស្សស្រីម្នាក់ដោយមនុស្សប្រុសជាអ្នកបើកម៉ូតូម៉ាកវីវ៉ា ពណ៌ខ្មៅ សណ្តោងរទេះដឹកសាកសពមនុស្សស្រីម្នាក់មកឈប់នៅក្បែររថយន្តដឹកសពរបស់ខ្លួន ហើយមនុស្សស្រីនោះបានដើរមកជួបអាចារ្យនៅកន្លែងតម្កល់សពក្នុងវត្តទឹកថ្លា ។ ពេលនោះឈ្មោះ ទិដ្ឋា បានសួរមនុស្សប្រុសនោះថា “ដឹកសពមកពីកន្លែងណា?” ប៉ុន្តែគាត់មិនចេះនិយាយភាសាខ្មែរទេ ហើយមនុស្សស្រីម្នាក់នោះបានដើរត្រឡប់មកវិញ លើកសពចេញពីក្នុងរទេះ ដោយឃើញពិបាកពេក ខ្លួននិងឈ្មោះ ទិដ្ឋា បានជួយលើកយកមកដាក់នៅសាលតម្កល់សព ហើយខ្លួន

បានយកទូរស័ព្ទដៃមកថតម៉ូតូសណ្តោងរទេះដឹកសាកសពមនុស្សស្រីនោះ ។ បន្ទាប់មកខ្លួននិងឈ្មោះ ទិដ្ឋា បានបើករថយន្តត្រឡប់ទៅវិញ ។

-អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted]វឿន បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ នៅថ្ងៃខែមិនចាំ ក្នុងឆ្នាំ១៩៩៨ ខ្លួនបានចាប់ផ្តើមប្រកបមុខរបរជាអ្នករត់ម៉ូតូឌុបនៅមុំផ្លូវរថភ្លើង គេហៅថាត្រឡោកបែក ។ រហូតដល់ឆ្នាំ២០១០ ខ្លួនបានស្គាល់ឈ្មោះ ធូ ភេទស្រី អាយុប្រហែល៤២ឆ្នាំ ជនជាតិវៀតណាម ជាអ្នកបើកហាងលក់កាហ្វេនិងចិញ្ចឹមស្រីបម្រើផ្លូវភេទ នៅផ្លូវលេខ៥៩៨ តាមរយៈខ្លួនធ្លាប់ឌុបឈ្មោះ ធូ ទៅផ្សារម្តុងម្ពាល និងធ្លាប់ប្រើឱ្យទៅទិញបបរនៅពេលយប់ ។ ចាប់ពីពេលដែលខ្លួនបានស្គាល់ឈ្មោះ ធូ គឺគាត់មានប្តីឈ្មោះ ស៊ាង អាយុប្រហែល៤៥ឆ្នាំ និយាយភាសាខ្មែរច្បាស់ ។ នៅពេលល្ងាចថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល១៧ និង៣០នាទី ខ្លួនបានបើកម៉ូតូម៉ាកវីវ៉ាពណ៌ខ្មៅស៊េរីចាស់ចេញពីបន្ទប់ជួលមករត់ម៉ូតូឌុបនៅផ្លូវរថភ្លើងដូចធម្មតា ។ រហូតដល់ម៉ោងប្រហែល១៨និង៣០នាទី ខ្លួនបានឃើញឈ្មោះ ធូ ជិះកង់មកហៅខ្លួនឱ្យឌុបទៅយកម៉ូតូនៅផ្សារទឹកថ្លា ។ ពេលឌុបឈ្មោះ ធូ ទៅដល់មុខផ្សារទឹកថ្លាឃើញប្អូនប្រុសរបស់គាត់ និងម៉ូតូស្កុបពីនៅកន្លែងជាង ដោយម៉ូតូនោះខូចម៉ាញ៉េតូ ហើយឈ្មោះ ធូ ក៏បានឡើងជិះម៉ូតូជាមួយខ្លួន ជិះរុញម៉ូតូប្អូនប្រុសរបស់គាត់ត្រឡប់មកផ្ទះវិញ ហើយឈ្មោះ ធូ បានសុំខ្ចីម៉ូតូរបស់ខ្លួនជិះមួយយប់ហើយខ្លួនក៏យល់ព្រមឱ្យដោយឈ្មោះ ធូ បានប្រាប់ថា “ចាំម៉ោង០៩ព្រឹកចាំមកយកម៉ូតូ” រួចហើយខ្លួនក៏ហៅម៉ូតូឌុបជិះត្រឡប់ទៅបន្ទប់ជួលវិញ ។ លុះព្រឹកឡើងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោង០៩ព្រឹក ខ្លួនបានជិះម៉ូតូឌុបទៅផ្ទះឈ្មោះធូ ដើម្បីយកម៉ូតូ ហើយឈ្មោះ ធូ បានឱ្យប្រាក់ខ្លួនចំនួន៦០.០០០ (ប្រាំមួយម៉ឺន) រៀល និងមាន់ស្ងោរមួយក្បាល ហើយខ្លួនក៏បានជិះម៉ូតូត្រឡប់ទៅបន្ទប់ជួលវិញ ។ រហូតដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល០៩ព្រឹកពេលដែលខ្លួនកំពុងឈរចាំឌុបម៉ូយក៏មានសមត្ថកិច្ចមកហៅខ្លួនមកសាកសួរនៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង ។ ចំពោះម៉ូតូរបស់ខ្លួនគឺបានទិញពីមនុស្សប្រុសម្នាក់នៅចុងឆ្នាំ២០១៧ ក្នុងតម្លៃ ៧៥០ (ប្រាំពីររយហាសិប) ដុល្លារអាមេរិក ដោយមានធ្វើលិខិតទិញលក់ត្រឹមត្រូវ និងមានប័ណ្ណសម្គាល់ម៉ូតូត្រឹមត្រូវ ។ អំពីភិនភាគឈ្មោះ ធូ ភេទស្រី អាយុប្រហែល៤២ឆ្នាំ ជនជាតិវៀតណាម ស្នាក់នៅផ្ទះលក់កាហ្វេ និងចិញ្ចឹមស្រីបម្រើផ្លូវភេទ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ មានភិនភាគមាឌរាងមានសាច់ សម្បុរស កម្ពស់ប្រហែល១.៦០ម៉ែត្រ សក់ស្គួតវែង ទម្រង់មុខទ្រវែង ភ្នែកតូចតឹង ចិញ្ចើមស្តើង ច្រមុះស្រួច មាត់តូច ពាក់អាវដៃខ្លីសាច់ក្រណាត់ ពណ៌លឿង មានផ្កាពណ៌ខ្មៅ ស្លៀកខោត្រឹមជង្គង់ ពណ៌លឿង មានផ្កាពណ៌ខ្មៅ (របៀបឈុត) និងយាយភាសាខ្មែរមិនច្បាស់ ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមអង្គសវនាការនេះឃើញថា ជនជាប់ចោទឈ្មោះ [redacted] យ៉ុងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានឆ្លើយបដិសេធថា៖ ជនជាប់ចោទទាំងពីរនាក់ពុំមែនជាអ្នកសម្លាប់ជនរងគ្រោះទេ ។ ប៉ុន្តែនៅថ្ងៃកើតហេតុ ជនជាប់ចោទទាំងពីរនាក់បានសារភាពថាពិតជាបានដឹកសាកសពជនរងគ្រោះទៅបូជានៅវត្តទឹកថ្លានប្រាកដមែន ។ ចម្លើយបដិសេធរបស់ជនជាប់ចោទទាំងពីរនេះគឺជាចម្លើយដោះសារយករួចខ្លួនតែប៉ុណ្ណោះ ពុំមានភស្តុតាងមកបង្ហាញជូនតុលាការដើម្បីពិចារណាឡើយ ។ ហេតុដូច្នេះ តំណាង**អយ្យការសុំតម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរលេខ២៣៣៦ អ.យ.ត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩** ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីខ្លួនទាំងពីរនាក់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ម្យ៉ាងវិញទៀត កូនក្តីខ្លួនបានសហការជាមួយសមត្ថកិច្ច ។ ខ្លួនមានឯកសារពេទ្យផ្សេងបានបញ្ជាក់ថា ជនរងគ្រោះពិតជាមានជម្ងឺ ។ បើតាមការប្រើអំបោសសម្រាប់អេសខ្លងនោះមិនអាចបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរនោះទេ ។ អំពើដែលកូនក្តីខ្លួនបានប្រព្រឹត្តពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ដូច្នេះខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនទាំងពីរនាក់ផង ។

-លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីហៀង បានធ្វើសេចក្តីសន្និដ្ឋានថា៖ ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានបដិសេធតាំងពីនៅមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងពេលសួរដេញដោលនេះ ។ កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើស មិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌនោះទេ។ ដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនផង ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ បានធ្វើសេចក្តីសន្និដ្ឋានថា៖ កូនក្តីរបស់ខ្លួនពិតជាបានប្រកបរបរកោសជប់មែន ។ ប៉ុន្តែពុំមានចម្លើយណាមួយដែលបានដាក់បន្ទុកមកលើកូនក្តីខ្លួននោះទេ ។ ម្យ៉ាងវិញទៀត ខ្លួនក៏ពុំដែលបានជួបជាមួយនឹងកូនក្តីខ្លួនដែរ ។ ដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនផង ។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសំណូមពរ សុំឱ្យតុលាការសម្រេចឱ្យខ្លួនបានរួចផុតពីបទចោទ ពីព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ជនជាប់ចោទឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បាននិយាយសម្តីចុងក្រោយថា៖ ខ្លួនសំណូមពរ សុំឱ្យតុលាការសម្រេច ឱ្យខ្លួនបានរួចផុតពីបទចោទ ពីព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ឡើយ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ បានជាសមត្ថកិច្ចឃាត់ខ្លួន និងបក្ខពួកឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីធូ ដែលត្រូវបានបងប្អូនជីដូនមួយ

ធ្វើសកម្មភាពវាយធ្វើទារុណកម្មលើឈ្មោះ យុង ភេទស្រី រហូតដល់ស្លាប់នៅចំណុចក្នុងផ្ទះជួល (បងស្រី) ផ្ទះលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ហើយយកសាកសពទៅចោលនៅសាលតម្កល់សពនៅក្នុងវត្តទឹកថ្លា កាលពីថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ខ្លួនរស់នៅប្រទេសកម្ពុជានៅឆ្នាំ២០០៥ ហើយនៅក្នុងឆ្នាំ២០១០ ខ្លួនបានជួលផ្ទះម៉ុផ្លូវរថភ្លើងត្រឡោកបែកប្រកបមុខរបរលក់ចាប់ហួយ ។ ចំណែកឈ្មោះ [redacted] ធីធូ ភេទស្រី ត្រូវជាបងជីដូនមួយបានជួលផ្ទះបើករកស៊ីផ្លូវភេទ ដោយមាននារី០២នាក់ឈ្មោះ ហៀង និងឈ្មោះ យុង (ជនរងគ្រោះ) ជាកូនចៅបំរើផ្លូវភេទ ។ រហូតដល់ក្នុងឆ្នាំ២០១៦ ឈ្មោះ [redacted] យ៉ាំងចូវ ត្រូវជាប្អូនជីដូនមួយដែរបានមកប្រទេសកម្ពុជា ដោយស្នាក់នៅផ្ទះជាមួយឈ្មោះ ធូ និងមើលការខុសត្រូវការរកស៊ីឲ្យឈ្មោះ ធូ ។ កន្លងមកខ្លួនតែងតែឃើញឈ្មោះ ចូវ ឈ្លោះគ្នាជាមួយឈ្មោះ យុង (ជនរងគ្រោះ) ជាញឹកញាប់ ។ រហូតដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោងប្រហែល២០និង០០នាទី ពេលខ្លួនកំពុងលក់ដូរលឺសម្លេងឈ្មោះ ចូវ ជជែកឈ្លោះគ្នាជាមួយជនរងគ្រោះនៅក្នុងផ្ទះបងស្រី ។ លុះដល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោងប្រហែល១៦និង០០នាទីឈ្មោះ ចូវ បានមកប្រាប់ខ្លួនថាឈ្មោះ យុង បានស្លាប់បាត់ហើយ ។ ពេលនោះ ខ្លួនបានឃើញរ៉ឺម៉កនិងម៉ូតូឈ្មោះ ចូវ និងឈ្មោះ ហៀង បានសែងសាកសពដែលរុំកន្ទេលស្រេចដាក់ក្នុងរ៉ឺម៉ក ដោយខ្លួនជាអ្នកជិះពីក្រោយអូសរទេះ ។ ចំណែកឈ្មោះ ចូវ ជាអ្នកបើកម៉ូតូយកទៅវត្តទឹកថ្លារួចក៏ទម្លាក់សាកសពនៅសាលតម្កល់សពបន្ទាប់មកក៏ត្រឡប់មកផ្ទះវិញ ។ នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោងប្រហែល០៦និង០០នាទី ក៏មានសមត្ថកិច្ចនាំខ្លួនទៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង ។ នៅក្នុងឆ្នាំ២០១៤ ខ្លួនធ្លាប់ពាក់ព័ន្ធបទល្មើសជួញដូរយកកូនស្រីបង្កើតអាយុ០៦ឆ្នាំទៅលក់បម្រើផ្លូវភេទ ត្រូវបាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌក្រសួងមហាផ្ទៃឃាត់ខ្លួនជាប់ពន្ធនាគារព្រៃស (ម២) រយៈពេល១៨ខែ ។ ចំពោះសារធាតុញៀនខ្លួនមិនដែលប្រើប្រាស់ទេ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ បានឆ្លើយនៅមន្ត្រីនគរបាលយុត្តិធម៌ថា៖ បានជាសមត្ថកិច្ចឃាត់ខ្លួនមកអធិការដ្ឋាននគរបាលខណ្ឌសែនសុខ ពីព្រោះខ្លួននិងបក្ខពួកឈ្មោះ [redacted] ធីយុង និងឈ្មោះ [redacted] ធីធូ បានធ្វើសកម្មភាពវាយធ្វើទារុណកម្មលើជនរងគ្រោះឈ្មោះ យុង ភេទស្រី រហូតដល់ស្លាប់នៅក្នុងផ្ទះជួល (បងស្រី) ផ្ទះលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ហើយយកសាកសពជនរងគ្រោះទៅដាក់រ៉ឺម៉កអូសម៉ូតូយកទៅទម្លាក់ចោលនៅសាលតម្កល់សពនៅក្នុងវត្តទឹកថ្លា ។ ឈ្មោះ [redacted] ធីយុង , ឈ្មោះ [redacted] ធីធូ និងខ្លួនត្រូវជាបងប្អូនជីដូនមួយរស់នៅប្រទេសវៀតណាម ។ បន្ទាប់មកឈ្មោះ [redacted] ធីយុង និងឈ្មោះ [redacted]ធូ បានចូលមកប្រកបមុខរបររកស៊ីក្នុងប្រទេសកម្ពុជាមុនរូបខ្លួន ។ លុះដល់ឆ្នាំ២០១៦ ឈ្មោះ [redacted] ធីយុង និងឈ្មោះ [redacted]ធូ បានយករូបខ្លួនមកប្រទេសកម្ពុជាដោយជួលផ្ទះលេខ១៥៩ ផ្លូវលេខ៥៩៨ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ បើកបនស្រីដោយឈ្មោះ ធូ និងឈ្មោះ យុង ជាមេបន ។ ចំណែករូបខ្លួនជាអ្នកមើលការខុសត្រូវ (កាងស្រី) ។ ស្រីបម្រើផ្លូវភេទនៅក្រោមការគ្រប់គ្រងរបស់ខ្លួនមានពីរនាក់មានឈ្មោះ [redacted] ធីយុង និងឈ្មោះ ហៀង ជាជនជាតិវៀតណាម ។ ពេលដែលខ្លួនឲ្យជនរងគ្រោះឈ្មោះ [redacted] ធីយុង ទៅទទួលភ្ញៀវភាគច្រើនតែងតែប្រកែកមិនព្រមទៅជាមួយភ្ញៀវ ហើយខ្លួនតែងតែវាយជាញឹកញាប់ ។ លុះដល់ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល២០ និង០០នាទី ឈ្មោះ [redacted]ធីយុង និងឈ្មោះ [redacted]ធីហៀង នៅជាមួយគ្នានៅក្នុងផ្ទះបនស្រី ខ្លួនបានឲ្យជនរងគ្រោះចូលរួមភេទជាមួយភ្ញៀវ ហើយជនរងគ្រោះប្រកែកជាមួយរូបខ្លួនមិនព្រម ខ្លួនក៏បង្ខំឲ្យចូល ។ ពេលជនរងគ្រោះចូលហើយបានយកលុយរបស់ភ្ញៀវ ។ ពេលនោះឈ្មោះ [redacted] ធីធូ បានមកដល់ហើយបញ្ជារឲ្យខ្លួន និងឈ្មោះ

[redacted] ធីយុង វាយជនរងគ្រោះ ដោយខ្លួនបានយកឈើឬស្សីសម្រាប់អេះខ្នងវាយជើង និងខ្លួនប្រាណ និងចាប់ក្បាលជនរងគ្រោះបោកនឹងជញ្ជាំងថ្មបែកគុម្ពត្រចៀក ហើយច្រានផ្កាប់មុខបណ្តាលឱ្យបែកថ្ងាស់ ។ ចំណែកឈ្មោះ [redacted] ធីយុង (បងស្រីខ្លួន) ជាអ្នកវាយនិងក្រញៀ៉ ខ្លួននិងបងស្រីបានវាយរហូតដល់ជនរងគ្រោះស្លាប់នៅវេលាម៉ោងប្រហែល១៦ និង០០នាទី ឈានចូលថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ។ ពេលនោះឈ្មោះ ធូ បានចាត់ចែងឱ្យឈ្មោះ ហៀង ជាអ្នកយកកន្ទេលមករុំសាកសព ។ ចំណែកឈ្មោះ [redacted] ធីយុង ជាអ្នករៀបចំរទេះដឹកសព ។ ចំណែករូបខ្លួនចុះទៅងូតទឹកហើយនៅម៉ោងប្រហែល២១និង០០នាទី ខ្លួននិងឈ្មោះ ហៀង បានសែងសាកសពជនរងគ្រោះចេញពីក្នុងផ្ទះមកដាក់លើរ៉ឺម៉ក ដោយខ្លួនជាអ្នកបើកម៉ូតូ និងឈ្មោះ [redacted] ធីយុង អង្គុយ ពីក្រោយអូសរទេះទៅវត្តទឹកថ្លាទម្លាក់នៅសាលតម្កល់សពរួចត្រឡប់មកដល់ផ្ទះកើតហេតុវិញ ហើយបានប្រាប់បងស្រីឈ្មោះ ធូ ជាអ្នកបញ្ជារថា ខ្លួនបានយកសពទៅបោះចោលរួចរាល់ហើយ ។ ខ្លួនបានទៅដេកនៅក្នុងផ្ទះឈ្មោះ ធូ ។ ចំណែកឈ្មោះ ហៀង បានចេញពីផ្ទះបនស្រីបាត់មិនដឹងទៅណាទេ ។ នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៨ ម៉ោង០១និង០០នាទី រំលងអាធ្រាតពេល ខ្លួនកំពុងនៅក្នុងផ្ទះបងស្រីឈ្មោះ [redacted] ធីយុង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនបញ្ជូនទៅអធិការដ្ឋាននគរបាលខណ្ឌសែនសុខតែម្តង ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានឆ្លើយបដិសេធនៅពេលសវនាការថា: ជនជាប់ចោទឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ពុំបានសម្លាប់ជនរងគ្រោះទេ ។ នៅ ថ្ងៃកើតហេតុជនជាប់ចោទទាំងពីរនាក់បានយករទេះអូសអេតចាយដឹកសពជនរងគ្រោះទៅបូជានៅវត្តទឹកថ្លា និងបានជូនលុយទៅលោកតាអាចារ្យចំនួន ៤០០.០០០ (សែសិបម៉ឺន) រៀល សម្រាប់ទុកធ្វើបុណ្យសព រួចហើយ ទើបជនជាប់ចោទទាំងពីរនាក់ត្រឡប់មកផ្ទះវិញ ។ ចម្លើយបដិសេធរបស់ជនជាប់ចោទទាំងពីរ គឺជាចម្លើយដោះសារយករួចខ្លួនតែប៉ុណ្ណោះ ពុំមានភស្តុតាងនិងសាក្សីមកបង្ហាញជូនតុលាការដើម្បីពិចារណាឡើយ ។ ចំណែកជនជាប់ចោទឈ្មោះ ង៉ៀង ធីហៀង និងឈ្មោះ [redacted] ចាន់ធូ ក្រោយពេលប្រព្រឹត្តបទល្មើសរួចហើយបានគេចខ្លួនបាត់ ។

៤-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត មានភាពស៊ីសង្វាក់គ្នាទៅនឹងអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ធីហៀង ព្រមទាំងសាក្សីឈ្មោះ [redacted] យ៉ាត់,ឈ្មោះ ឡូ ផាត់ និងឈ្មោះ [redacted] សុផល , អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ម៉ាលីន , ឈ្មោះ [redacted] មុន្នីវិជ្ជា , ឈ្មោះ [redacted] ម៉េងហេង និងឈ្មោះ [redacted] វឿន ព្រមទាំងភស្តុតាងផ្សេងទៀតដែលមាននៅក្នុងសំណុំរឿងបានបញ្ជាក់ថា: កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅចំណុចបន្ទប់ជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ពិតជាមានករណី **ផ្តើមគំនិតនៃអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ , ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ** និងមិនប្តឹងបរិហារបទឧក្រិដ្ឋ **និងការលើកលែង** មួយបានកើតឡើង ដែលបង្កដោយជនជាប់ចោទចំនួន០៤នាក់មានឈ្មោះ [redacted] យ៉ាំងចូវ , ឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត , ឈ្មោះ [redacted] ធីហៀង និងឈ្មោះ [redacted] ចាន់ធូ ។ មុនពេលកើតហេតុនៅដើមឆ្នាំ២០១៧ ជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ បានមកជួលផ្ទះបើកមុខរបរដាក់ស្រីបម្រើផ្លូវភេទ ដែលមានជនរងគ្រោះឈ្មោះ [redacted] ធីយុង ហៅ យុង និងឈ្មោះ [redacted] ធីហៀង ជាអ្នកទទួលភ្ញៀវ ហើយឈ្មោះ គីម ចាន់ធូ បានឱ្យឈ្មោះ [redacted] យ៉ាំងចូវ ជាអ្នកគ្រប់គ្រងមើលការខុសត្រូវលើនារីទាំងពីរនាក់នោះ នៅពេលដែលនារីទាំងពីរនាក់នោះពុំព្រមទទួលភ្ញៀវ ។ លុះក្រោយមកនៅថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ ស្រាប់តែជនរងគ្រោះឈ្មោះ [redacted] ធីយុង ហៅ យុង មានអាការៈពុំស្ញូវស្រួលខ្លួនមិនព្រមទទួលភ្ញៀវ ទើបឈ្មោះ [redacted] ចាន់ធូ មានការខឹង និងបានបញ្ជារឱ្យឈ្មោះ

[redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត វាយមកលើជនរងគ្រោះ ដោយឈ្មោះ [redacted] យ៉ាំងចូវ បានយកឈើឫស្សីសម្រាប់អេះខ្នងវាយជើង ខ្លួនប្រាណ និងចាប់ក្បាលជនរងគ្រោះបោកនឹងជញ្ជាំងថ្មបែកគុម្ពត្រចៀក ហើយច្រានផ្កាប់មុខបណ្តាលឱ្យបែកថ្ងាស់ ។ ចំណែកឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ជាអ្នកវាយនិងក្រញ៉ាំរហូតដល់ជនរងគ្រោះស្លាប់ ។ បន្ទាប់មកឈ្មោះ [redacted] ចាន់ធូ បានចាត់ចែងឱ្យឈ្មោះ [redacted] ធីហៀង ជាអ្នកយកកន្ទេលមករុំសាកសព ។ ចំណែកឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ជាអ្នករៀបចំរទេះអីកសព ។ ចំណែកឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ ហៀង បានសែងសាកសពជនរងគ្រោះចេញពីក្នុងផ្ទះមកដាក់លើរ៉ឺម៉ក ដោយខ្លួនជាអ្នកបើកម៉ូតូ ហើយឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ជាអ្នកអង្គុយពីក្រោយអូសរទេះអីកទៅវត្តទឹកថ្លាដើម្បីទម្លាក់នៅសាលតម្កល់សពប្រាកដមែន។

**៥-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ , ឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត , ឈ្មោះ [redacted] ធីហៀង និងឈ្មោះ [redacted] ចាន់ធូ ក្នុងពេលប្រព្រឹត្ត និងក្រោយពេលប្រព្រឹត្តជននេះមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវអំពើរបស់ខ្លួន និងចំពោះមុខក្រមព្រហ្មទណ្ឌជាធរមាន។**

**៦-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត** បានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៧-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធីហៀង បានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌ។

៨-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ បានប្រព្រឹត្តមានធាតុផ្សំគ្រប់គ្រាន់ជាបទល្មើសដែលមានបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា ២៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

៩-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានចេតនាទុច្ចរិត បង្កឱ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១០-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ធីហៀង បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានចេតនាទុច្ចរិត បង្កឱ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សង្គម និងប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌ ។

១១-អំពើរបស់ជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ បានបង្ហាញឱ្យឃើញថាគ្រប់សកម្មភាពមុន និងក្នុងពេលប្រព្រឹត្ត ក៏ដូចជាក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទមានចេតនាទុច្ចរិត បង្កឱ្យមានការខូចខាតដល់សណ្តាប់ធ្នាប់សង្គម ប៉ះពាល់ដល់នីត្យានុកូលភាពសង្គមបំពានលើមាត្រា២៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១២-តំណាងអយ្យការប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការលើកយកមកធ្វើការពិចារណា និងសម្រេច។

**១៣-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ** និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ថា៖ កូនក្តីខ្លួនទាំងពីរនាក់មិនបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ ម្យ៉ាងវិញទៀត កូនក្តីខ្លួនបានសហការជាមួយសមត្ថកិច្ច ។ ខ្លួនមានឯកសារពេទ្យផ្សេងបានបញ្ជាក់ថាជនរងគ្រោះពិតជាមានជម្ងឺ ។



Scanned with CamScanner

បើតាមការប្រើអំបោសសម្រាប់អេសខ្នងនោះមិនអាចបង្កឱ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរនោះទេ ។ អំពើដែលកូនក្តីខ្លួនបានប្រព្រឹត្ត ពុំមានធាតុផ្សំគ្រប់គ្រាន់ក្នុងការចោទប្រកាន់ពីបទហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌនោះទេ។ ដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនទាំងពីរនាក់ផង ។ ចំណុចនេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

១៤-សេចក្តីសន្និដ្ឋានរបស់លោកស្រីមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ធីហៀង ថា៖ ជនជាប់ចោទឈ្មោះ [redacted] យ៉ាំងធូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត បានបដិសេធតាំងពីនៅមន្ត្រីនគរបាលយុត្តិធម៌ អយ្យការ និងពេលសួរដេញដោលនៅពេលនេះ ។ កូនក្តីខ្លួនមិនបានប្រព្រឹត្តបទល្មើសមិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនផង ។ ចំណុចនេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

១៥-សេចក្តីសន្និដ្ឋានរបស់លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ថា៖ កូនក្តីរបស់ខ្លួនពិតជាបានប្រកបរបររកាសជប់មែន ។ ប៉ុន្តែពុំមានចម្លើយណាមួយដែលបានដាក់បន្ទុកមកលើកូនក្តីខ្លួននោះទេ ។ម្យ៉ាងវិញទៀត ខ្លួនក៏ពុំដែលបានជួបជាមួយនឹងកូនក្តីខ្លួនដែរ ។ ដូច្នេះ ខ្លួនសំណូមពរ សុំឱ្យតុលាការមេត្តាធ្វើការលើកលែងការចោទប្រកាន់មកលើកូនក្តីខ្លួនផង ។ ចំណុចនេះ គប្បីតុលាការលើកយកមកធ្វើការពិចារណា។

១៦-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] យ៉ាំងធូវ ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិវៀតណាម និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណេត ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិវៀតណាម ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

១៨-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៣៤ឆ្នាំ ជនជាតិវៀតណាម ពីបទ មិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌ។

១៩-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិវៀតណាម ពីបទ ផ្តើមគំនិតនៃអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។

២០-វត្ថុចាប់យករួមមានរទេះរុញសដៃចំនួន០១ , ទូរស័ព្ទដៃម៉ាក HUAWEI ពណ៌ខៀវ ចំនួន០១គ្រឿង (មិនដំណើរការ) , ឈើកែច្នៃសម្រាប់អេះខ្នងចំនួន០២ដើម គប្បីតុលាការពិចារណានិងសម្រេចតាមមាត្រា៦២ និងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌ ។



Scanned with CamScanner

២១-ជនជាប់ចោទឈ្មោះ [redacted] ធីហៀង ត្រូវបានចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ៣៥៧ (ង).ដ.ច.ន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ ។ បន្ថែមពីនេះ ទោសដែលត្រូវប្រកាសលើជនជាប់ចោទឈ្មោះ ង្វៀង ធីហៀង នោះជាបទមជ្ឈិម ដែលតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០១ (មួយ) ខែ ទៅ០១ (ឆ្នាំ) និងពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។ ហេតុនេះ គប្បីតុលាការបញ្ឈប់ដីកាឱ្យចាប់ខ្លួនលើជនជាប់ចោទរូបនេះ។

២២- ជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ក្រោយពីប្រព្រឹត្តបទល្មើសរួច មិនទទួលស្គាល់កំហុសរបស់ខ្លួន ព្រមទាំងបានរត់គេចខ្លួន ។ ទង្វើទាំងនេះសរបញ្ជាក់ឱ្យឃើញថាជនជាប់ចោទទាំងពីររូបនេះគ្មានចេតនាកែប្រែខ្លួនដើម្បីចូលមករស់នៅក្នុងសង្គមវិញនោះទេ។ បន្ថែមពីនេះ ទោសដែលត្រូវបានប្រកាសលើជនជាប់ចោទឈ្មោះ គីម ចាន់ធូ ជាបទឧក្រិដ្ឋ ។ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចឱ្យចាប់ខ្លួនលើជនជាប់ចោទរូបនេះ តាមមាត្រា៣៥៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>ហេតុដូច្នេះទើបវិនិច្ឆ័យសេចក្តី</u>

១-ផ្តន្ទាទោសលើជនជាប់ចោទដែលមានឈ្មោះដូចខាងក្រោម:

១.១-ឈ្មោះ [redacted] យ៉ាំងធូវ ភេទប្រុស អាយុ២៤ឆ្នាំ សញ្ជាតិវៀតណាម (មានសាវតាជាតិដូចខាងលើ)

១.២-ឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ុំណេត ភេទស្រី អាយុ៣៥ឆ្នាំ សញ្ជាតិវៀតណាម (មានសាវតាជាតិដូចខាងលើ)

**ដាក់ពន្ធនាគារក្នុងម្នាក់ៗកំណត់០៨ (ប្រាំបី) ឆ្នាំ ពីបទ ហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។**

២-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៣៤ឆ្នាំ សញ្ជាតិវៀតណាម (មានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ពីបទមិនប្តឹងបរិហារបទឧក្រិដ្ឋ និងការលើកលែង ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា៥២៩ នៃក្រមព្រហ្មទណ្ឌ ។**

៣-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិ ដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០៨ (ប្រាំបី) ឆ្នាំ ពីបទ ផ្តើមគំនិតនៃអំពើហិង្សាដោយចេតនាមានស្ថានទម្ងន់ទោសដោយសារមរណភាពនៃជនរងគ្រោះ ប្រព្រឹត្តនៅចំណុចផ្ទះជួលលេខ១៥៨ ផ្លូវលេខ៥៩៨ ក្រុមទី៦២ ភូមិ១៦ សង្កាត់ទឹកល្អក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៨ តាមបញ្ញត្តិមាត្រា២៨ និងមាត្រា២២៤ នៃក្រមព្រហ្មទណ្ឌ ។**

៤-បញ្ឈប់ដីកាបង្គាប់ឱ្យចាប់ខ្លួនលើជនជាប់ចោទឈ្មោះ [redacted] ធីហៀង ភេទស្រី អាយុ៣៤ឆ្នាំ សញ្ជាតិវៀតណាម (មានសាវតាជាតិដូចខាងលើ) លេខ៣៥៧ (ង).ដ.ច.ន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ។

៥-បង្គាប់ឱ្យចាប់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ចាន់ធូ ភេទស្រី អាយុ៣៨ឆ្នាំ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដើម្បីយកមកអនុវត្តទោសតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៦-វត្ថុចាប់យកមានរទេះរុញសរដៃចំនួន០១ , ឈើកែច្នៃសម្រាប់អេះខ្នងចំនួន០២ដើម និងទូរស័ព្ទដៃម៉ាក HUAWEI ពណ៌ខៀវ ចំនួន០១គ្រឿង (មិនដំណើរការ) ត្រូវរឹបអូស។

៧-សាលក្រមនេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] យ៉ាំងចូវ និងឈ្មោះ [redacted] ធីយុង ហៅ [redacted] ស៊ីណាត , កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ធីហៀង និងឈ្មោះ [redacted] ចាន់ធូ និងប្រកាសជាសាធារណៈនៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ។

ទុកប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ថ្ងៃសុក្រ ០៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
| --- | --- | --- | --- |
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃសុក្រ ០៧កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ,ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ក្រឡាបញ្ជី**

[redacted]